# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៣០៩.អក.ភព-៩៧

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

**លោកព្រះរាជអាជ្ញាអមតុលាការក្រុង ភ្នំពេញ**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ</u>:** អំពីការជួញដូរផ្លូវភេទនឹងចាប់ពង្រត់ឱ្យធ្វើសីបេស្យា ។

**<u>យោង</u>:** ព្រឹត្តិប័ត្រអ្នកជា ឆ្នាំទី៤ លេខ ៩៦ ចេញផ្សាយ ថ្ងៃទី១៥-១១-៩៧ ។

ខ្ញុំសូមជម្រាបលោកថា ព្រឹត្តិប័ត្រដូចមានចែងក្នុងកម្មវត្ថុខាងលើបញ្ជាក់ថា នៅក្រុងភ្នំពេញមានការជួញដូរផ្លូវភេទកាន់តែរីកដុះដាលច្រើនឡើងៗធ្វើឱ្យប្រទេសយើងកាន់តែចុះអន់ថយទៅៗ មិនអាចឈានទៅកាន់នីតិវត្តបាន ។ ជាពិសេសនៅតាមផ្ទះបននីមួយៗ សុទ្ធសឹងតែមានមន្ត្រីដែលមានឋានៈខ្ពស់ដូចជា មន្ត្រីយោធា មន្ត្រីនគរបាលការពារឱ្យមេបនបើកអាជីវកម្មនេះទៀតផង ។

ក្នុងករណីនេះ សូមលោកព្រះរាជអាជ្ញាមានវិធានការបើកវគ្គបំពាក់បំប៉នដល់មន្ត្រីនគរបាល ព្រមទាំងមន្ត្រីកងរាជអាវុធហត្ថឱ្យបានយល់និងអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ហើយមានប្រសិទ្ធិភាពចំពោះការវិវត្តរបស់សង្គមខ្មែរយើង ។

ទី១ -ខ្ញុំសូមបញ្ជាក់ថា ច្បាប់មិនសំដៅយកទោសពៃលើស្រីបស្យាផ្ទាល់ខ្លួន ដែលឥតអ្នកណាបង្ខិតបង្ខំគំរាមកំហែងធ្វើបាបឱ្យទទួលរួមរក្សជាមួយភ្ញៀវយកលុយមកឱ្យមេបននោះទេ។ ច្បាប់នេះសំដៅកំចាត់បំផ្លាញមេបននិងពួកការពារមេបន អ្នកចាប់បង្ខាំងស្ត្រីរងគ្រោះឱ្យរួមរក្សជាមួយភ្ញៀវ ។ ខ្ញុំសូមទាញអារម្មណ៍របស់អស់លោកជាពិសេសទៅលើជំពូកទី៣ ដែលចែងអំពីសញ្ចារិកម្មសញ្ចារិកា ( បានន័យថាមេបស្យាឬមេបន ) ក្នុងមាត្រា៤ ចំនុចទី៥ ដែលចែងថា៖ នឹងត្រូវចាត់ទុកជាសញ្ចារិកម្មសញ្ចារិកា ឬជាមេបនបេស្យា ជនណាដែលឱ្យបុរសឬស្ត្រីនៅក្នុងផ្ទះរបស់ខ្លួនឬកន្លែងណាមួយ ក្នុងគោលដៅឱ្យជនទាំងនោះធ្វើបេស្យាចារយកប្រាក់ឱ្យខ្លួន ។

<u>មាត្រា៥</u> ចែងថា សញ្ចារិកម្មសញ្ចារិកា ឬជនជាមេបេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំ ទៅ១០ឆ្នាំ ក្នុងករណីមិនរាងចាលត្រូវយកទ្វេគុណនៃទោសមកអនុវត្ត ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ដល់ ២០ឆ្នាំ ក្នុងករណីសញ្ចារិកម្ម៖

១-ប្រព្រឹត្តបទល្មើសលើអនីតិជនអាយុក្រោម ១៥ឆ្នាំ ។

២-ប្រព្រឹត្តបទល្មើសដោយបង្ខិតបង្ខំវិហឹង្សា ឬដោយមានការគំរាមកំហែង ឬដោយមានអាវុធ ។

ខ្ញុំសូមបញ្ជាក់ម្តងទៀតថាច្បាប់នេះមិនសំដៅលើការបំបាត់ពេស្យាចារទេ ពីព្រោះឥតមានប្រទេសណានៅលើសកលលោកបំបាត់បេស្យាចារបានតាមបំណងទេ គឺសំដៅមិនឱ្យធ្វើអាជីវកម្មលើមនុស្ស និងសំដៅកុំឱ្យជម្ងឺអេដស៍ រីករាលដាលពេញប្រទេស ដោយមានវិធានការអប់រំ និងត្រួតពិនិត្យពីក្រសួងមានសមត្ថកិច្ច ។

ចំពោះជនល្មើសដែលនគរបាលឬកងរាជអាវុធហត្ថបានចាប់បញ្ជូនមកតុលាការ តុលាការត្រូវផ្តន្ទាទោសជាអតិបរមានៃទោសដែលមានកំណត់ក្នុងច្បាប់ ដូចក្រសួងបានណែនាំតាមលិខិតលេខ៩៧៨ ព្ររ.៣.២.៩៧ ចុះថ្ងៃទី១០-០៩-៩៧ ដែលចម្លងជូនភ្ជាប់មកជាមួយនេះ ។

ខ្ញុំសូមទាញអារម្មណ៍ជាពិសេស ចំពោះអស់លោកព្រះរាជអាជ្ញាលោកចៅក្រមស៊ើបសួរព្រមទាំងនគរបាលយុត្តិធម៌ទាំងអស់ ឱ្យយកចិត្តទុកដាក់អនុវត្តច្បាប់នេះឱ្យបានតឹងរឹងបំផុត ពីព្រោះក្រសួងយុត្តិធម៌បានទទួលព័ត៌មានជាញឹកញាប់ណាស់ថា អស់លោកនគរបាលមួយចំនួនទុកលទ្ធភាពមានករណីខ្លះជំរុញឱ្យធ្វើផងឱ្យជនប្រព្រឹត្តល្មើសធ្វើការសម្រុះសម្រួលជាមួយគ្រួសារជនរងគ្រោះ ដោយឱ្យលុយបន្តិចបន្តួចឱ្យបញ្ឈប់ការប្តឹងផ្តល់ ។

ខ្ញុំសូមជម្រាបអស់លោកព្រះរាជអាជ្ញាថា អស់លោកមានភារកិច្ចទទួលខុសត្រូវចំពោះរបៀបរៀបរយសាធារណៈនិងការគោរពសិទ្ធិជាសារវន្តរបស់មនុស្ស ជាពិសេសការពារសិទ្ធិរបស់អនីតិជន ។ បើមានករណីខាងលើនេះកើតឡើងលោកជាអ្នកទទួលខុសត្រូវមុនគេជាមួយនគរបាលយុត្តិធម៌ ។ ខ្ញុំសូមបញ្ជាក់ម្តងទៀតថាច្បាប់មិនអនុញ្ញាតឱ្យយករឿងព្រហ្មទណ្ឌមកសម្រុះសម្រួលតាមសំណងរដ្ឋប្បវេណីឡើយ (មាត្រា៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ)។

ខ្ញុំសូមអស់លោកអនុវត្តច្បាប់នេះ ឱ្យបានតឹងរឹងបំផុត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្នួន**

<u>ចម្លងជូន</u>

-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ ព្រះរាជាធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សូមមេត្តារាយការណ៍ថ្វាយមហាក្សត្រ ទ្រង់ព្រះមេត្តាជ្រាប
-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម(ខុទ្ទកាល័យសម្តេចប្រមុខរដ្ឋស្តីទី ព្រះរាជតំណាងព្រះមហាក្សត្រ) ។
-ទីស្តីការគណៈរដ្ឋមន្ត្រី
-តុលាការកំពូលនិងសាលាឧទ្ធរណ៍
-តុលាការខេត្ត.ក្រុង
-រដ្ឋសភា គណៈកម្មការការពារសិទ្ធិមនុស្ស
-ក្រសួងមហាផ្ទៃ នគរបាលយុត្តិធម៌
-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងកិច្ចការនារី
-ក្រសួងសង្គមកិច្ច
-ក្រសួងសុខាភិបាល
-ក្រសួងអប់រំនិងកីឡា
-ក្រសួងព័ត៌មាន
-កាលប្បវត្តនិងឯកសារ